Higher School Certificate (HSC) minimum standard parent meeting request

# សំណើប្រជុំសម្រាប់ឪពុកម្តាយស្តីពីស្តង់ដារអប្បរមាវិញ្ញាបនបត្រមធ្យមសិក្សា (HSC)

Name of student
ឈ្មោះសិស្ស

Name of parent
ឈ្មោះឪពុកម្តាយ

Date for meeting
កាលបរិច្ឆេទសម្រាប់ការប្រជុំ

ជូនចំពោះឪពុកម្តាយ / អ្នកថែរក្សា

ខ្ញុំសរសេរលិខិតនេះដើម្បីរំលឹកអ្នកអំពីស្តង់ដារអប្បរមា HSC។ ដើម្បីឱ្យសិស្សទទួលបានសញ្ញាបត្រ HSC ពួកគេត្រូវតែទទួលបានកម្រិតអក្ខរកម្ម និងការគិតរាប់លេខអប្បបរមា។ ស្តង់ដារអប្បបរមាត្រូវបានកំណត់ដោយការធ្វើតេស្តតាមអនឡាញលើការអាន ការសរសេរ និងការគិតរាប់លេខ។

នៅដំណាក់កាលនេះ កូនរបស់អ្នកមិនទាន់បានទទួលស្តង់ដារអប្បបរមា HSC នៅឡើយទេ ហេតុដូច្នេះហើយនេះគឺជាការប្រឈមនឹងហានិភ័យនៃការមិនទទួលបានសញ្ញាបត្រ HSC ។

កូនរបស់អ្នកមិនបានបំពេញតាមស្តង់ដារផ្នែក៖

- ☐ Reading
  ការអាន
- ☐ Numeracy
  ការគិតរាប់លេខ
- ☐ Writing
  ការសរសេរ

ខ្ញុំមានបំណងផ្តល់ឱ្យកូនរបស់អ្នកនូវរាល់ឱកាសដើម្បីទទួលបានស្តង់ដារអប្បបរមា HSC ហើយផ្តល់ឱ្យអ្នកនូវរាល់ឱកាសដើម្បីគាំទ្រដល់ពួកគេសម្រេចបានស្តង់ដារនេះ។

ខ្ញុំចង់អញ្ជើញអ្នកមកចូលរួមការប្រជុំពិភាក្សាមួយ តាមកាលបរិច្ឆេទដូចបានបង្ហាញខាងលើ ដើម្បីឱ្យអ្នក និងកូនរបស់អ្នក និងសាលារៀនអាចពិភាក្សាជាមួយគ្នាអំពីផែនការសិក្សារបស់កូនអ្នក។ ការពិភាក្សានេះនឹងរាប់បញ្ចូលគោលបំណងរបស់កូន អ្នកអំពី HSC ការគាំទ្រផ្នែកអក្ខរកម្ម និងការគិតរាប់លេខដែលមានផ្តល់ជូន ហើយនិងជម្រើសក្រោយការរៀនសូត្រនៅសាលា។ ការចូលរួមរបស់អ្នកមានសារៈសំខាន់ណាស់។

លទ្ធផលតេស្តស្តង់ដារអប្បបរមា HSC មានផ្តល់ជូននៅលើគណនី Student Online (អនឡាញសិស្ស) របស់កូនអ្នក នៅតាមវ៉ិបសៃថ៍របស់អាជ្ញាធរស្តង់ដារអប់រំ រដ្ឋ NSW (NESA)។ យើងនឹងមានច្បាប់ចតចម្លងនៅឯការប្រជុំ។

ប្រសិនបើអ្នកត្រូវការអ្នកបកប្រែភាសានៅឯកិច្ចប្រជុំនេះ សូមទាក់ទងមកសាលារៀន ដែលនឹងរៀបចំឱ្យមានម្នាក់ជូនអ្នក ប្រសិនបើអាចរកបាន។

## សេវាកម្មអ្នកបកប្រែភាសាតាមទូរស័ព្ទ

ប្រសិនបើអ្នកត្រូវការអ្នកបកប្រែភាសាដើម្បីជួយអ្នកទាក់ទងមកសាលារៀន សូមទូរស័ព្ទទៅសេវាកម្មអ្នកបកប្រែភាសាតាម ទូរស័ព្ទលេខ 13 14 50 ហើយស្នើសុំអ្នកបកប្រែជាភាសារបស់អ្នក។ ប្រាប់ប្រតិបត្តិករនូវលេខទូរស័ព្ទដែលអ្នកចង់ហៅ ហើយប្រតិបត្តិករនឹងរៀបចំអ្នកបកប្រែភាសាតាមទូរស័ព្ទជូនអ្នកសម្រាប់ការសន្ទនា។ អ្នកនឹងមិនត្រូវគេគិតថ្លៃសម្រាប់សេវាកម្មនេះទេ។

ដោយក្តីគោរព

នាយកសាលា (Principal)

ព័ត៌មានបន្ថែមស្តីពីគោលការណ៍ស្តង់ដារអប្បបរមា HSC អាចរកបាននៅតាមវ៉ិបសៃថ៍ NESA
https://educationstandards.nsw.edu.au/wps/portal/nesa/11-12/hsc/hsc-minimum-standard